## IV-ព្យាបាល និងការការពារ :

### ក-ព្យាបាល

ប្រើប្រាស់ថ្នាំមួយចំនួនដូចខាងក្រោម :

-Triclabendazole (Fasinex) កំរិត ១២ម.ក្រ/គក្រ ទំងន់សត្វរស់ ដោយបញ្ចូកតាមមាត់ ។

-Albendazole កំរិត ១៥ម.ក្រ/គ.ក្រ ទំងន់សត្វរស់ ដោយបញ្ចូកតាមមាត់ ។

-Nilzan កំរិត ១៥ម.ក្រ/គ.ក្រ ទំងន់សត្វរស់ដោយ បញ្ចូកតាមមាត់ ។

-Nitroxinile (Dovenix-25%) ចាក់ក្រោមស្បែកកំរិត ១ម.ល/២៥គ.ក្រ ទំងន់សត្វរស់ ។

-Oxyclozanide កំរិត ១៥ម.ក្រ/គ.ក្រ ទំងន់សត្វរស់ ដោយបញ្ចូកតាមមាត់ ។












### ខ-ការការពារ

-ប្រមូលលាមកសត្វ រក្សាក្នុងរណ្តៅរយៈពេលយ៉ាងតិច ពីរខែ មុននឹងយកទៅប្រើប្រាស់ជាជី ។ ធ្វើយ៉ាងនេះអាច កំចាត់ស៊ុតព្រូនហ្វាស្យូឡាបាន ។

-បញ្ចៀសសត្វផឹកទឹក ស៊ីស្មៅ រុក្ខជាតិទឹក គល់ជញ្ជាំងជា ទឹកន្លែងឆ្លងជំងឺ ។

-ចៀសវាងផ្តល់ចំណី ដូចជាស្មៅរុក្ខជាតិទឹកមានប្រភពពី កន្លែងឆ្លងជំងឺ ។

-បំបាត់ខ្យងលីមណេអា ដែលជាម្ចាស់កណ្តាលព្រូន ហ្វាស្យូឡា ដោយការចិញ្ចឹមទា និងត្រី ។



បញ្ចៀសសត្វផឹកទឹក ស៊ីស្មៅ រុក្ខជាតិទឹកជាទីកន្លែងឆ្លងជំងឺ

នាយកដ្ឋាន ផ.ប

ACIAR

# ជំងឺបង្កដោយព្រូនហ្វាស្យូឡា

# (Fasciolosis)



គំរោង ACIAR , AS1/2002/099

រៀបចំដោយ : នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល
នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម
#៧៤ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ ភ្នំពេញ
Tel/Fax : 023 991 839
E-mail: Sothoeundahp@online.com.kh

2004

ជំងឺបង្កដោយព្រូនហ្វាស្យូឡា បណ្តាលមកពីព្រូនសំប៉ែត ត្រេម៉ាតូត (Trematode) ប្រភេទហ្វាស្យូឡាហ្គីហ្គង់ទីកា (Fasciola gigantica)កើតលើសត្វស្រុក និងព្រៃច្រើនប្រភេទ ជាពិសេស គោ ក្របី ចៀម និងពពែ ។

ជំងឺនេះបណ្តាលអោយសត្វស្គមចុះទំងន់ មួយចំនួនតូច ងាប់ ផលិតភាពបន្តពូជទាប ថ្លើមខូច ផលិតផលថយចុះ ហើយ សត្វមិនសូវមានកំលាំងមាំមួន ។ល ។

## I-ទំរង់និងរូបរាង :

ព្រូនមានរាងសំប៉ែត ពណ៌ប្រផេះ ត្នោត ប្រវែង ៣,៥-៧,៥ ស.ម ខ្លួនមានរាងស្របគ្នាផ្នែកក្បាល ( ស្មាមុខ)និងកន្ទុយ ។ ប្រវែង ស្មាមុខ និងកន្ទុយ មានប្រវែង ០,៦៥ -១,២ ស.ម ។

## II-វដ្តជីវិត :

ព្រូនហ្វាស្យូឡារស់នៅក្នុងថ្លើម បញ្ចេញស៊ុតមកក្រៅ តាមរយៈលាមក រយៈពេលពី ១០-១២ថ្ងៃ ស៊ុតញាស់បានជា មីរ៉ាស៊ីដ្យូម (Miracidium) ។ មីរ៉ាស៊ីដ្យូមនៅក្នុងទឹកជ្រាត ចូលក្នុងខ្យងលីមណេអា (Lymnaea) ដែលជាម្ចាស់កណ្តាល របស់ព្រូនហ្វាស្យូឡា ។ នៅក្នុងខ្យងលីមណេអា មីរ៉ាស៊ីដ្យូម លូតលាស់ និងក្លាយជា ស្ព័រូស៊ីស (Sporocyst) រ៉េដ្យា (Rediae) និងសែការីយ៉ា (Cercariae) ដែលរយៈពេល លូតលាស់ពីមីរ៉ាស៊ីដ្យូមដល់សែការីយ៉ា មានពី ៤-៧ សប្តាហ៍ ។ សែការីយ៉ាចេញពីខ្យងលីមណេអា តោងស្មៅ រុក្ខជាតិដុះក្នុងទឹក ស្រូវ ។ល ។ ហើយក្លាយជាគីស្តដែលហៅថា មេតាសែការីយ៉ា (Metacercaria) ។ សត្វត្រូវបានឆ្លងដោយសារ បានលេប ផឹក ស៊ីស្មៅ រុក្ខជាតិទឹក ( គល់ជញ្ជ្រាំង ឬ ចំបើង) មានមេតាសែ-ការីយ៉ា ។ ករណីខ្លះជំងឺអាចឆ្លងទៅកូនតាមរយះសុក កូនព្រូន ហ្វាស្យូឡា ត្រូវបាននាំទៅថ្លើមហើយរស់នៅទីនោះ រហូតដល់ ពេញវ័យ ។




**វដ្តជីវិតព្រូនហ្វាស្យូឡា**



**ខ្យងលីមណេអា**



**ទីកន្លែងរស់នៅខ្យងលីមណេអា**

## III-រោគសញ្ញា :

-សត្វរាគអាចម៍ ពិសេសលាមកជាប់គូថមានពណ៌ក្រមៅ

-រោមស្ងួត បាស់ ស្រអាប់

-ស្គម ចុះទំងន់

-ហើមត្របកភ្នែក ភ្នាសត្របកភ្នែកស្លេក លឿង

-ហើមម៉ុំថ្គាម និងទ្រូង